# អ្នកនាំសារ

The Messenger

34

ខែឧសភា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ

## ជីវិតថ្មីដ៏រុងរឿង!





គ្រោះថ្នាក់ចរាចរណ៍គឺជាវិបត្តិថ្មីនៃសង្គម
ទំព័រ ៨



ព្រះសហគមន៍នៅបន្តជួយជនក្រីក្រ
ទំព័រ ១០

មិនជាសត្រូវដ៏ធំរបស់មនុស្សជាតិ
ទំព័រ ១២

## សំនួរក្មេងៗ

### តើព្រះយេស៊ូជាព្រះអម្ចាស់


Photo: DR

ម្ដេចក៏ព្រះអង្គសោយទិវង្គត? បើព្រះអង្គសោយទិវង្គតលើឈើឆ្កាងមែន តើព្រះអង្គមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងរហូតមកដល់សព្វថ្ងៃឬយ៉ាងណា?

តាមរូបកាយ ព្រះយេស៊ូពិតជាស្លាប់។ ពួកទាហានរ៉ូម៉ាំងដឹងយ៉ាងច្បាស់ ហើយគេមានជំនាញខាងសម្លាប់នេះឯង។ ច្បាស់ណាស់ ព្រះយេស៊ូមានរូបកាយដូចយើង។ រូបកាយយើងត្រូវស្លាប់ ប៉ុន្តែ វិញ្ញាណរបស់យើងគឺមិនស្លាប់ឡើយ។

តើព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងរហូតមកដល់សព្វថ្ងៃនេះ?

ពិតណាស់! ព្រះយេស៊ូពិតជាមានព្រះជន្មរស់ឡើងវិញប្រាកដមែន។ សាវ័កជាច្រើនបានឃើញព្រះអង្គ។ ក្នុងគម្ពីរបញ្ជាក់ច្បាស់ថា រូបកាយព្រះអង្គមិនស្លាប់ទេ។ ព្រះអង្គមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។ ព្រះអង្គគង់ជាមួយយើងនៅសព្វថ្ងៃនេះដែរ។ មានប្រមាណជា ១១ដង ដែលគម្ពីរបញ្ជាក់ថា ព្រះយេស៊ូពិតជាមានព្រះជន្មវិញដ៏រុងរឿង។

តើរឿងនេះកើតឡើងដូចម្ដេច?

ព្រះយេស៊ូខុសពីមនុស្សយើង។ ព្រះអង្គជាមនុស្សផង និងជាព្រះអម្ចាស់ផង។ ព្រះអង្គសោយរាជ្យលើអ្វីៗទាំងអស់។ ព្រះអង្គមានឫទ្ធានុភាព ទោះបីមនុស្សបានសម្លាប់រូបកាយព្រះអង្គ ប៉ុន្តែព្រះអង្គមានអំណាចធ្វើឱ្យរូបកាយនេះរស់ឡើងវិញ។ ពេលរូបកាយព្រះអង្គរស់ឡើងវិញដ៏រុងរឿង ព្រះអង្គបានយាងចេញពីផ្នូរ។ នៅថ្ងៃដែលព្រះយេស៊ូសោយទិវង្គត ផ្នូរខ្មោចជាច្រើនបានរបើកហើយសពប្រជាជនដ៏វិសុទ្ធបានរស់ឡើងវិញ (ម៉ាថាយ ២៧,៥២-៥៣)។ សពទាំងនោះបានស្លាប់យូរមកហើយ ប៉ុន្តែក៏រស់ឡើងវិញដោយសារឫទ្ធានុភាពដ៏រុងរឿងរបស់ព្រះយេស៊ូ។

លី សុវណ្ណា

## អធិប្បាយព្រះបន្ទូល

### ថ្ងៃទី ២៣ មេសា ២០០៦ ថ្ងៃអាទិត្យទី ២ នៃបុណ្យចម្លង

## “សូមអោយអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត”

(យហ ២០,១៩-២៩)

“យើងបានឃើញព្រះអម្ចាស់!” ក្រុមសាវ័កមានបទពិសោធន៍ដ៏អស្ចារ្យ ដែលមិនអាចប្រកែកបាន និងរកថ្លែងមិនបានដែរ គឺលោកយេស៊ូ ដែលជាមេដឹកនាំសាសនារបស់គេត្រូវបានឆ្កាង និងសម្លាប់ចោលយ៉ាងសែនអាម៉ាស។ ព្រះជាម្ចាស់ “បានប្រោសលោកឱ្យក្រោកឡើងវិញពីចំណោមមនុស្សស្លាប់” លោកទទួលព្រះជន្មដ៏រុងរឿងហើយ! លោកទទួលឋានៈជា “ព្រះគ្រីស្ដ និងជាព្រះអម្ចាស់” ហើយប្រទានព្រះវិញ្ញាណរបស់ព្រះអង្គឱ្យពួកគេ។ នេះគឺជាការអស្ចារ្យដែលផ្ដល់សេចក្ដីសុខសាន្ត គឺអំណរសប្បាយយ៉ាងខ្លាំងឱ្យពួកគេ។ ព្រះជាម្ចាស់មិនបានលះបង់មនុស្សសុចរិត ដែលត្រូវគេធ្វើបាបឡើយ គឺព្រះអង្គលើកលោកឡើង និងតែងតាំងលោកឱ្យមានឋានៈស្មើនឹងព្រះអង្គ។

ដូច្នេះក្រុមសាវ័ករៀបរាប់ថា ទោះបើទ្វារបិទជិតក៏ដោយ ក៏គេបាន “ឃើញ” ព្រះយេស៊ូគង់នៅជាមួយគេ បានសេចក្ដីថា ព្រះអង្គមានព្រះជន្មតាមរបៀបប្លែកពីគ្រាមុន។ លោកថូម៉ាស់ចង់ “ស្ទាប” ព្រះអង្គថែមទៀត។ តាមពិត គេ “ឃើញ” និង “ស្ទាប” ព្រះអង្គដោយសារជំនឿតែប៉ុណ្ណោះ។ នៅពេលយើងជួបជុំគ្នាដូចពួកគេនៅថ្ងៃអាទិត្យ ក៏យើងជឿយ៉ាងពិតប្រាកដថា ព្រះយេស៊ូគង់នៅជាមួយយើងមែន។ យើងគឺជាព្រះកាយព្រះគ្រីស្ដ។ យើងរួមជាមួយព្រះអង្គដែលបូជាព្រះជន្ម និងទទួលព្រះជន្មដ៏រុងរឿង។ យើងក៏ដូចជា “ឃើញ” និង “ស្ទាប” ព្រះយេស៊ូដោយសារជំនឿរបស់យើង ដូចជាពួកគេដូច្នោះដែរ។

អ្នកដទៃឃើញព្រះយេស៊ូសម្ដែងឫទ្ធានុភាពព្រះអង្គដោយសារយើង ជាពិសេស ដោយយើងលើកលែងទោសឱ្យគ្នា គឺយើងនាំសេចក្ដីសុខសាន្តដ៏ពិតប្រាកដឱ្យមនុស្សលោក។

### ថ្ងៃទី ៣០ មេសា ២០០៦ ថ្ងៃអាទិត្យទី ៣ នៃបុណ្យចម្លង

## “ព្រះយេស៊ូបំភ្លឺគំនិតគេអោយយល់អំពីអត្ថន័យគម្ពីរ”

(លក ២០,១៩-៣១)

ព្រះយេស៊ូដែលតើនពីចំណោមមនុស្សស្លាប់ មិនគ្រាន់តែមានវិញ្ញាណប៉ុណ្ណោះទេ ព្រះអង្គមានទាំងព្រះកាយដ៏រុងរឿងថែមទៀត។ ជនជាតិក្រិកតែងយល់ឃើញថា ពេលមនុស្សស្លាប់ វិញ្ញាណក្ខន្ធរបស់គេបានសេរីភាព និងបានសេចក្ដីសុខ ហើយក៏មិនត្រូវការឱ្យមានរូបកាយរស់នៅតទៅទៀតឡើយ។ ហេតុនេះហើយបានជា លោកលូកាខិតខំបញ្ជាក់ ឱ្យគ្រីស្ដបរិស័ទជាតិក្រិកជឿជាក់ច្បាស់ថា ព្រះយេស៊ូគង់នៅយ៉ាងពិតប្រាកដមែន មានព្រះកាយដ៏រុងរឿងដែលអាចឃើញ និងស្ទាបបាន ហើយព្រះអង្គសោយព្រះក្រយាទៀតផង។ នេះសុទ្ធតែជារបៀបបញ្ជាក់ឱ្យបានច្បាស់ថា ព្រះអង្គមានព្រះកាយដ៏រុងរឿង និងមានព្រះជន្មគង់នៅពិតប្រាកដមែន ដែលមិនគ្រាន់តែជាព្រះវិញ្ញាណរបស់ព្រះយេស៊ូ ដែលរស់ឡើងវិញប៉ុណ្ណោះទេ។

ប៉ុន្តែជំនឿរបស់គេ ក៏ដូចជំនឿរបស់យើងដែរ គឺមកពីព្រះយេស៊ូបំភ្លឺចិត្តគំនិតគេឱ្យយល់ពីអត្ថន័យនៃព្រះគម្ពីរ និងយល់អំពីអត្ថន័យនៃសក្ការៈបូជារបស់ព្រះអង្គ។ នៅពេលព្យាការីយេស៊ូ ដែលជាមនុស្សសុចរិតរងទុក្ខលំបាក ព្រះអង្គស្រឡាញ់ព្រះបិតាក្នុងនាមមនុស្សលោកទាំងអស់។ ...



... ព្រះបិតាក៏សព្វព្រះហឫទ័យនឹងសក្ការៈបូជារបស់លោក ហើយតែងតាំងលោកជាព្រះគ្រីស្ដ និងជាព្រះអម្ចាស់។ ហេតុនេះហើយបានជា មនុស្សគ្រប់ជាតិសាសន៍មានផ្លូវឆ្ពោះទៅកាន់ព្រះបិតាដោយចិត្តសង្ឃឹម និងដោយផ្ញើជីវិតទាំងស្រុងទៅលើព្រះយេស៊ូ។

នេះជាអំណរសប្បាយដែលយើងចង់ចែកចាយដល់មនុស្សឯទៀតៗ ឱ្យជឿដូចយើងដែរ។

### ថ្ងៃទី ៧ ឧសភា ២០០៦ ថ្ងៃអាទិត្យទី ៤ នៃបុណ្យចម្លង

## “ខ្ញុំជាគង្វាលដ៏ល្អ”

(យហ ១០,១១-១៨)

ក្នុងគម្ពីរ ពាក្យ “គង្វាល” សំដៅទៅលើអ្នកដឹកនាំស្រុក ឬសាសនាយូដា ដែលមានព្រះមហាក្សត្រ និងអស់លោកបូជាចារ្យជាដើម។ ព្រះយេស៊ូប្រថុយជីវិតដើម្បីការពារកូនចៅរបស់ព្រះអង្គ ដូចជាគង្វាលតែងប្រថុយជីវិតការពារហ្វូងសត្វរបស់ខ្លួន។ តែព្រះអង្គមានសេរីភាពពេញទីក្នុងពេលបូជាព្រះជន្ម គ្មាននរណាបង្ខំព្រះអង្គឡើយ មានតែសេចក្ដីស្រឡាញ់ប៉ុណ្ណោះ ដែលជំរុញឱ្យព្រះអង្គបូជាព្រះជន្ម។ នៅក្នុងគម្ពីរ ពាក្យ “ស្គាល់” ក៏មានអត្ថន័យថា “ស្រឡាញ់” ដែរ ព្រះអង្គស្រឡាញ់យើងម្នាក់ៗ ទុកជាមនុស្សមានតម្លៃ ក្នុងឋានៈជាបុត្រធីតារបស់ព្រះបិតាដែរ។

ព្រះអង្គស្រឡាញ់មនុស្សទាំងអស់ មិនគ្រាន់តែស្រឡាញ់ចំពោះគ្រីស្ដបរិស័ទប៉ុណ្ណោះទេ។ យើង និងអ្នកកាន់សាសនាដទៃប្លែកពីគ្នាត្រង់សេចក្ដីមួយ គឺយើងជឿថា ព្រះអង្គស្រឡាញ់យើង។ ជីវិតយើងមានតម្លៃដ៏ខ្ពង់ខ្ពស់ ចំណែកឯអ្នកដទៃមិនស្គាល់ឋានៈរបស់ខ្លួនទេ។ យើងត្រូវតែចែកអំណរសប្បាយរបស់ខ្លួន ក្នុងឋានៈជាបុត្រធីតារបស់ព្រះបិតាឱ្យគេស្គាល់ ទើបអ្នកដទៃ នឹងចង់ស្គាល់ព្រះបិតានោះហើយ “អំណរសប្បាយរបស់យើងបានពេញលក្ខណៈ”។

### ថ្ងៃទី ១៤ ឧសភា ២០០៦ ថ្ងៃអាទិត្យទី ៥ នៃបុណ្យចម្លង

## “អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ... ទើបបង្កើតផលជាច្រើន”

(យហ ១៥,១-៨)

ក្នុងគម្ពីរ អ្នកនិពន្ធតែងប្រៀបធៀបប្រជារាស្ត្រនៃព្រះជាម្ចាស់ទៅនឹងចំការទំពាំងបាយជូរមួយ ឬដូចជាដើមទំពាំងបាយជូរមួយដើម។ ព្រះជាម្ចាស់ថែទាំចំការអស់ពីសមត្ថភាព តែចំការនោះផ្ដល់តែផ្លែអាក្រក់ប៉ុណ្ណោះ។ ដូច្នេះព្រះយេស៊ូមានព្រះបន្ទូលប្រៀបខ្លួនព្រះអង្គផ្ទាល់ទៅនឹងដើមទំពាំងបាយជូរមួយដើមដែលបង្កើតផលផ្លែស្របតាមព្រះហឫទ័យនៃព្រះបិតា។ ព្រះយេស៊ូគឺជាតំណាងរបស់ប្រជារាស្ត្រដែលគាប់ព្រះហឫទ័យព្រះបិតា។ អ្នកណានៅជាប់នឹងព្រះយេស៊ូដោយសារជំនឿ អ្នកនោះទទួលព្រះជន្មផ្ទាល់របស់ព្រះអង្គក្នុងខ្លួន និងអាចគាប់ព្រះហឫទ័យព្រះបិតាបាន។ យើងជាគ្រីស្ដបរិស័ទ បង្ហាញអំពីព្រះជន្មដ៏រុងរឿងរបស់ព្រះយេស៊ូដែលកំពុងមានសកម្មភាពនៅក្នុងខ្លួនយើង។ សន្តបុគ្គលទាំងឡាយមិនមែនជាវីរបុរសប្រព្រឹត្តការអស្ចារ្យទេ គឺជាអ្នកដែលជឿលើព្រះយេស៊ូ និងទុកឱ្យព្រះអង្គសំដែងឫទ្ធានុភាពរបស់ព្រះអង្គក្នុងខ្លួនគេ។ យើងមិនមែនជាអ្នកខិតខំធ្វើបុណ្យធ្វើទានទេ គឺយើងជាអ្នកដែលទុកឱ្យព្រះយេស៊ូបំពេញសកម្មភាពផ្សេងៗ ក្នុងខ្លួនយើង។ យើងអធិដ្ឋានរួមជាមួយនិងព្រះយេស៊ូ ទើបព្រះបិតាទទួលស្គាល់នូវពាក្យអធិដ្ឋានយើងទុកជាការអធិដ្ឋានរបស់ព្រះយេស៊ូ ជាព្រះបុត្រា តែយើងក៏ត្រូវមានចិត្តគំនិតដូចព្រះយេស៊ូដែរ។

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!**



## ភាពស្និទ្ធស្នាលក្នុងគ្រួសារ

រដូវ៤០ថ្ងៃ កន្លងទៅ ព្រះសហគមន៍បាននាំយើងរិះគិតលើប្រធានបទ “គ្រួសារ”។ នៅក្នុងខែនេះ អ្នកនាំសារ សូមលើកយកប្រធានបទដដែលនេះមករិះគិតរួមគ្នា។ តើមានអ្វីដែលអាចជួយយើងឱ្យកាន់តែស្និទ្ធស្នាលរវាងគ្នានិងគ្នា? តើមានអ្វីដែលអាចជួយយើងឱ្យចេះចំណាយពេលច្រើនជាងចំពោះគ្នានិងគ្នា? តើមានអ្វីដែលអាចជួយយើងឱ្យចេះយកចិត្តទុកដាក់ដល់គ្នាទៅវិញទៅមក? តើនៅក្នុងគ្រួសារ យើងគួរប្រព្រឹត្តដូចម្ដេចខ្លះ? អ្នកនាំសារ សូមផ្ដល់ជាគំនិតខ្លះៗ ដូចតទៅនេះ: សូមយកពេលខ្លះដើម្បីនិយាយលេងជាមួយកូនៗ ឬធ្វើអ្វីមួយរួមគ្នាដើម្បីកំសាន្ត។ ឪពុកម្ដាយជាគំរូដល់កូនៗ និងបង្រៀនកូនអំពីវត្តមាននៃសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់។ សូមយកពេលវេលាខ្លះដើម្បីអធិដ្ឋានរួមគ្នាក្នុងគ្រួសារ។ ប្រសិនបងប្អូនពុំធ្លាប់ សូមសាកល្បង។ វាមានការលំបាកបន្តិចពេលចាប់ផ្ដើមដំបូង តែសូមកុំបោះបង់។ អធិដ្ឋានក្នុងពេលបរិភោគអាហារ និងរកពេលណាដែលគ្រួសារនៅជុំគ្នាដើម្បីអធិដ្ឋាន។ បងប្អូនអាចប្រើសៀវភៅអធិដ្ឋានរបស់ព្រះសហគមន៍ ឬក៏ធម៌ផ្កាំដើម្បីសូមឱ្យព្រះនាងម៉ារីជួយគ្រួសារយើងឱ្យរីកចម្រើន ឡើងនៅក្នុងជំនឿរបស់ខ្លួនជានិច្ច។ សូមដាក់ ឬព្យួរឈើឆ្កាងនៅជញ្ជាំងក្នុងផ្ទះ ឬរូបព្រះនាងម៉ារី ហើយពន្យល់ដល់កូនថា គ្រួសារមានការរីករាយណាស់ ដែលបានចូលរួមក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់។

ទាំងនេះគ្រាន់តែជាចំនុចខ្លះៗ ប៉ុណ្ណោះ។ បងប្អូនមានរបៀបផ្សេងៗ ជាច្រើនទៀតតាមបទពិសោធន៍ជាក់ស្ដែងផងដែរ។ សូមព្រះនាងម៉ារីជួយណែនាំផ្លូវយើងជានិច្ច!

អ្នកនាំសារ

## បុណ្យចម្លង មណ្ឌលគីរី



Photo: S. Metrey

កាលពីថ្ងៃទី៩ មេសា ជាអាទិត្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ ព្រះសហគមន៍ប៊ូស្រានៅខេត្តមណ្ឌលគីរី នៃភូមិភាគកំពង់ចាម បានធ្វើបុណ្យចម្លង ដែលត្រូវដឹកនាំដោយលោកបូជាចារ្យអេនរីកូ ហ្វីដាន់ហ្សា។ នាឱកាសនោះ មានគ្រីស្តបរិស័ទ និងនិស្សិតមកពីមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកភ្នំពេញចូលរួមយ៉ាងកុះករ។ តាមប្រសាសន៍របស់គ្រីស្តបរិស័ទវ័យចំណាស់ម្នាក់ បានឱ្យដឹងថា ព្រះសហគមន៍ប៊ូស្រាមានគ្រីស្តបរិស័ទជាង២០០នាក់ ហើយធម្មតាអភិបូជាធ្វើតែនៅពេលមានបូជាចារ្យមកប៉ុណ្ណោះ។ គាត់បន្តថា បើគ្មានបូជាចារ្យ គ្រីស្តបរិស័ទគ្រាន់តែអធិដ្ឋានរួមគ្នា។

សុខ ពង្សមេត្រី

## សម្ពោធអគារសិក្សាថ្មី កំពង់ធំ



Photo: L. Sovanna

អគារសិក្សា ៣ខ្នង មាន ១៨បន្ទប់ ដែល ២បន្ទប់ជាអនុវិទ្យាល័យ ថ្នាក់ទី៧ និងទី៨ គឺជាអំណោយរបស់ព្រះសហគមន៍កាតូលិក ជូនប្រជាពលរដ្ឋក្រីក្រនៅភូមិកំពង់គោក្រោម ឃុំកំពង់គោលើ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២៣ មីនា ឆ្នាំ២០០៦ កន្លងទៅក្រោមអធិបតីភាពលោកបូជាចារ្យទម្លាប់ សុផល តំណាងពេញសិទ្ធិរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង លោកអភិបាលរងទី១ ខេត្តកំពង់ធំ ប្រធានមន្ទីរខេត្ត អាជ្ញាធរជុំវិញស្រុក ប្រជាពលរដ្ឋ និងសិស្សានុសិស្សប្រមាណជា ៣០០នាក់។ លោកបូជាចារ្យទម្លាប់ សុផល បានបញ្ជាក់ថា: "នេះជាការឆ្លើយតបចំពោះសំណូមពររបស់អាណាព្យាបាលសិស្ស និងចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍នៃរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពអវិជ្ជា និងភាពក្រីក្រ"។ សំណង់នេះបានចំណាយអស់ទឹកប្រាក់ចំនួន១១៦០៣៤,៥២$។

ភាព

## អេម៉ានូអែល សម្លេងពីព្រះសហគមន៍កាតូលិក



បាត់ដំបង: FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

## ហម តឿន ជីវិតក្នុងក្រុមសហជីវិនព្រះយេស៊ូ



Photo: L. Sovanna

នេះជាលើកទីមួយហើយ ដែលមានយុវជនខ្មែរយើងបានស្ម័គ្រចិត្តចូលក្នុងក្រុមបព្វជិត សហជីវិនព្រះយេស៊ូ ក្រោយពីការចាប់កំណើតជាថ្មីនៃព្រះសហគមន៍នៅកម្ពុជា។ លោកហម តឿន ជាយុវជនមកពីព្រះសហគមន៍បាត់ដំបង បានចាកចេញពីប្រទេសកម្ពុជាកាលពីថ្ងៃទី១១ មេសា ឆ្នាំ២០០៦ កន្លងទៅ ដើម្បីទៅបន្តការសិក្សាក្នុងក្រុមបព្វជិត សហជីវិនព្រះយេស៊ូនៅប្រទេសសាំងហ្គាពួរ រយៈពេល ២ឆ្នាំដំបូង។ លោកបានប្រាប់ឱ្យដឹងថា: "នេះគឺជាការសាកល្បងដើម្បីឆ្លើយតបដល់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះខ្ញុំ"។ សម្រាប់ទៅថ្ងៃអនាគត ទៅជាយ៉ាងណានោះ លោកសូមពឹងផ្អែកលើព្រះជាម្ចាស់ទៅចុះ។ លោកបន្ត ដោយធ្វើការអធិដ្ឋានសម្រាប់បងប្អូនដែលមានជំនឿ និងអធិដ្ឋានសម្រាប់យុវជន យុវនារី រួមនិងរូបលោក ដែលបានស្ម័គ្រចិត្តដើរតាមផ្លូវផ្សេងៗ ក្នុងក្រុមអ្នកបម្រើព្រះយេស៊ូ។

លី សុវណ្ណា

## អង្គប្រជុំកែសម្រួលសៀវភៅ



Photo: L. Sovanna

ដោយមានតម្រូវការចាំបាច់របស់ព្រះសហគមន៍ក្នុងការកែសម្រួលពាក្យមួយចំនួនដែលកំពុងប្រើប្រាស់នៅក្នុងព្រះសហគមន៍ និងដើម្បីឱ្យបានសមស្របតាមជំនឿ និងតាមទំនៀមទម្លាប់ប្រពៃណីខ្មែរនោះ លោកអភិបាលទាំងបី បានសម្រេចបង្កើតនូវក្រុមប្រឹក្សាមួយដែលមានតំណាងគ្រប់ភូមិភាគចូលរួម តាមសំណើរបស់មជ្ឈមណ្ឌលវប្បធម៌កាតូលិកកម្ពុជា។ ក្រុមនេះ បានជួបជុំគ្នា១លើក រួចមកហើយ កាលថ្ងៃទី២៤ មីនា ២០០៦ និងការជួបលើកទីពីរនេះ គឺធ្វើកាលពីថ្ងៃទី១៩ មេសា ២០០៦កន្លងទៅ ដែលដឹកនាំដោយលោកអភិបាលអេមីល ដេតម្ប។

សុវណ្ណា



## ក្មេងពិការទទួលជីវិតថ្មី

នៅមណ្ឌលបងស្រីមេត្តាករុណា ចោមចៅ មានកុមារចំនួន៥នាក់ ទទួលបុណ្យជ្រមុជទឹកក្រោមអធិបតីភាពរបស់លោកអភិបាលអេមីល ដេតម្ប។ បងស្រីមេត្តាករុណា មានប្រសាសន៍ថា: "ខ្ញុំរៀបចំដល់ពួកគេ ពីព្រោះក្មេងៗទាំងអស់នេះ មានបញ្ហាខួរក្បាល ជាពិសេសឪពុកម្តាយរបស់គេបានផ្តាំផ្ញើឱ្យជួយមើលថែទាំកូនៗរបស់គេ មុនពេលពួកគេស្លាប់ ហើយខ្ញុំក៏ឃើញនូវការកម្រើកខ្លួន ដែលបង្ហាញនូវការយល់ព្រមរស់នៅជាមួយព្រះយេស៊ូ នៅពេលលោកឪពុកគូសសញ្ញាឈើឆ្កាង"។

ធារី

## ការធ្វើពិធីសំណាក់ធម៌

នាថ្ងៃទី១ មេសា ឆ្នាំ២០០៦ មានកម្មវិធីសំណាក់ធម៌ ដែលប្រព្រឹត្ត នៅព្រះសហគមន៍ពោធិ៍សាត់ ក្នុងមណ្ឌលកសិដ្ឋានគ្រាប់ ដោយមានការចូលរួមពីលោកពុកពេជ្រ ក្រុមសង្គហៈ ក្រុមរៀបចំបុណ្យ គ្រូអប់រំជំនឿ និងក្រុមតំណាងយុវជនព្រះសហគមន៍បាត់ដំបងចំនួន ១៦នាក់។ កម្មវិធីនេះទទួលការណែនាំពីលោកពុកពេជ្រ ក្នុងគោលបំណង ឱ្យបងប្អូនរិះគិតស្វែងយល់ពីព្រះគម្ពីរ និងពីដំណើរជីវិតជាគ្រីស្តបរិស័ទ។ លោកពុកឱ្យដឹងថា: "នេះគឺធ្វើឡើងដើម្បីឱ្យបងប្អូន រិះគិត និងអធិដ្ឋានរួមគ្នាក្នុងនាមយើងអ្នកបម្រើព្រះសហគមន៍"។

សុជាតិ

## ប្រសិទ្ធពរប្រេងនៃអគ្គសញ្ញា



Photo: L. Sovanna

កាលពីថ្ងៃព្រហស្បតិ៍មុនសប្តាហ៍ពិសិដ្ឋ មានពិធីប្រសិទ្ធពរលើប្រេងសម្រាប់អគ្គសញ្ញាផ្សេងៗ ក្រោមអធិបតីភាពរបស់លោកអភិបាលនៃព្រះសហគមន៍ភូមិភាគទាំងបី និងមានការចូលរួមពីសំណាក់អស់លោកបូជាចារ្យទាំងអស់គ្រប់ភូមិភាគ និងគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

សុវណ្ណា



Photo: P. Samphy

ទិដ្ឋភាពក្នុងសាលប្រជុំពិភាក្សាតុមូលរវាងអន្តរសាសនា

## ជំនួបអន្តរសាសនាពង្រឹងសីលធម៌

កាលពីថ្ងៃទី១៨ មេសា ឆ្នាំ២០០៦ កន្លងទៅ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ រាជធានីភ្នំពេញ មានការពិភាក្សាតុមូលមួយលើប្រធានបទ "មូលដ្ឋានគ្រឹះនៃសីលធម៌ និងក្រមសីលធម៌សង្គម" ដែលបានការចូលរួមពីមេដឹកនាំ និងតំណាងសាសនាធំៗ នៅកម្ពុជា មាន ពុទ្ធសាសនា ឥស្លាមសាសនា និងគ្រីស្តសាសនា និកាយកាតូលិក និងប្រូតេស្តង់ និងត្រូវបានរៀបចំឡើងដោយមូលនិធិខុនរ៉ាដអាដិនណូអ៊ែរ អាឡឺម៉ង់ សហការនិងក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា។

នៅក្នុងឱកាសនោះ ភិក្ខុយស ហ៊ុត ខេមចារោ ទីប្រឹក្សាក្រុមអន្តរសាសនាមានសង្ឃដីកាថា: "ពុទ្ធសាសនា បានបង្រៀនឱ្យមនុស្សម្នាក់ៗ មានតុល្យភាពខាងក្តីមេត្តាករុណា និងបញ្ញាជាដរាប ហើយយើងគប្បីត្រូវយកសីលធម៌នេះទៅប្រើជាក់ស្តែងនៅក្នុងជីវិតរស់នៅ"។ ចំណែកឯកឧត្តម ហ្សាការីយ៉ា អាដាម តំណាងនៃសាសនាឥស្លាមបានលើកឡើងថា: "ពាក្យថា "ឥស្លាម" ប្រែមកថា "ធ្វើឱ្យមានសន្តិភាព"។ ទង្វើណាមួយដែលជនមូស្លីមធ្វើផ្ទុយពីពាក្យនេះ គឺពុំត្រឹមត្រូវតាមអ្វីដែលសាសនាឥស្លាមចង់បាននោះទេ"។ រីឯលោកបូជាចារ្យ អ៊ុន សុន តំណាងឱ្យព្រះសហគមន៍កាតូលិក នៅកម្ពុជា ក៏មានប្រសាសន៍ដែរថា: "គោលបំណងនៃគ្រីស្តសាសនា គឺអប់រំអ្នកជឿឱ្យរស់នៅដោយពឹងផ្អែកលើព្រះបន្ទូល និងធ្វើតាមព្រះហប្ញទ័យព្រះបិតា គឺស្រលាញ់ព្រះជាម្ចាស់អស់ពីចិត្តគំនិត និងស្រឡាញ់អ្នកដទៃឱ្យដូចជាស្រឡាញ់ខ្លួនឯងដែរ"។

ជាទីបញ្ចប់លោក លី ធន់ ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអន្តរសាសនា បានពោលថា ឥទ្ធិពលនៃសកលភាវូបនីយកម្មកែប្រែផ្នត់គំនិតមនុស្ស ឱ្យផ្តល់តម្លៃហួសហេតុទៅលើសម្ភារៈ ដែលធ្វើឱ្យពួកគេមានការប្រកួតប្រជែង និងមិនចុះសម្រុងគ្នា។ [illegible]

សំភី

# កម្រងរូបថតអនុស្សាវរីយ៍ថ្ងៃបុណ្យចម្លង ២០០៦

## ភ្នំពេញ





ឆ្វេង: ១. ពិធីព្រះពរភ្លើងនៅផ្សារតូច។ ២. គ្រីស្តបរិស័ទអធិដ្ឋានក្នុងវិហារ នាឱកាសបុណ្យចម្លង។ ៣. បងប្អូនដែលទើបនឹងទទួលអគ្គសញ្ញាជ្រមុជទឹក។ ស្តាំ: ១. ពិធីលាងជើងនៅពោធិ៍សាត់។ ២. គោរពព្រះយេស៊ូដែលសុគត។






## បាត់ដំបង





១. ពិធីព្រះពរភ្លើង។ ២. ពិធីហែទៀនជ័យនៅកំពង់ធំ។ ៣. លោកបូជាចារ្យង៉ែត វិន័យ ធ្វើពិធីជ្រមុជទឹកដល់បងប្អូនស្វែងយល់ហើយ។ ៤. គ្រីស្តបរិស័ទថ្មីទទួលព្រះពន្លឺព្រះគ្រីស្តមកគង់ក្នុងជីវិត។ ៥. ពិធីបាចទឹកព្រះពរដល់គ្រីស្តបរិស័ទ។





Photos: L. Sovanna, V. Sambath, R. Bora, H. Sokhtheary

១. លោកអភិបាលអេមីល ដេតម្ប ធ្វើពិធីជ្រមុជទឹកដល់អ្នកស្វែងយល់នាឱកាសបុណ្យចម្លង។ ២. លោកអភិបាលលាបប្រេងដល់កុមារក្នុងពិធីទទួលអគ្គសញ្ញាជ្រមុជទឹកនៅមណ្ឌលបងស្រីមេត្តាករុណា ចោមចៅ ភ្នំពេញ។ ៣. ការថតរូបរួមគ្នារវាងឪពុកម្ដាយធម៌ និងក្មេងពិការដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក។



ពិធីព្រះពរទឹកដែលរៀបចំធ្វើឡើងនៅព្រះសហគមន៍ព្រែកស្បូវ កំពង់ធំ។

## កំពង់ចាម



១. ពិធីដើរផ្លូវព្រះឈើឆ្កាង។ ២. អភិបូជាបុណ្យចម្លង។ ៣. ទទួលព្រះកាយលើកដំបូង។ ៤. ពិធីប្រសិទ្ធពរដល់បងប្អូនគ្រីស្តបរិស័ទ។





# គ្រោះថ្នាក់ចរាចរណ៍ គឺជាវិបត្តិថ្មីនៃសង្គម

**ក្រៅពីបញ្ហាជំងឺអេដស៍ និងមីនដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាស្លាប់ និងរបួសជារៀងរាល់ថ្ងៃ លើដងផ្លូវនានា បញ្ហាគ្រោះថ្នាក់ចរាចរណ៍បានក្លាយជាប្រធានបទដ៏សំខាន់មួយ ដែលទាំងរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិកំពុងតែយកចិត្តទុកដាក់តាមដាន និងចាត់វិធានការក្នុងគោលបំណងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ។**



ការបើកបរមិនប្រុងប្រយ័ត្ននឹង នាំមកនូវសោកនាដកម្មដ៏ធ្ងន់ធ្ងរ

Photo: HIB

### គ្រោះថ្នាក់ចេះតែកើន

តាមប្រសាសន៍របស់អ្នកស្រីប្រាក់ ពិសិដ្ឋរង្សី ជាប្រធាននាយកដ្ឋានការពារសុខភាព របស់ក្រសួងសុខាភិបាល បានឱ្យដឹងអំពី តួលេខនៅឆ្នាំ២០០៥ ដែលបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ មានសភាពធ្ងន់ធ្ងរ គឺក្នុងមួយថ្ងៃមានមនុស្សស្លាប់ បីនាក់ នៅក្នុងក្របខណ្ឌ ទូទាំងផ្ទៃប្រទេស។

ចំណែក កញ្ញាសាន សុជាតា ដែលជាមន្ត្រីកម្មវិធីអប់រំសុវត្ថិភាពចរាចរណ៍ នៃអង្គការ Handicap International និយាយថា អត្រានៃករណីគ្រោះថ្នាក់នេះ នៅតែមានទំនោរកើនឡើង ជាប្រាកដតទៅទៀត ដោយសារប្រជាពលរដ្ឋមានការកើនច្រើនឡើងៗ ទាំងចំនួនយានយន្ត និងផ្លូវក្រាលកៅស៊ូក៏កើន ដែលបណ្ដាលឱ្យមាន ការប៉ះទង្គិច និងគ្រោះថ្នាក់ច្រើនផងដែរ។ ជាក់ស្ដែងនៅពេលចូលឆ្នាំខ្មែរកន្លងទៅនេះ បើតាមទិន្នន័យពីប៉ូលីសចរាចរណ៍ ក្រសួងមហាផ្ទៃ នៅទូទាំងប្រទេស គឺមានប្រជាជនស្លាប់ ៤៧នាក់ និង៥៥០នាក់ ទៀតរងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍។ តួលេខនេះគឺមានការកើនឡើង បើប្រៀបធៀបជាមួយនិងឱកាសចូលឆ្នាំខ្មែរ នាឆ្នាំ២០០៥ ដែលមានតែ ៣៣នាក់ស្លាប់ និង៤២៨នាក់រងរបួសប៉ុណ្ណោះ។

### ទីតាំង ជនរងគ្រោះ និងពេលវេលា

ទិន្នន័យរបស់អង្គការ Handicap International ចាប់តាំងពី ខែកញ្ញា ឆ្នាំ២០០៥ ដល់ ខែកុម្ភៈ ឆ្នាំ២០០៦ បានឱ្យដឹងថា ជាប្រចាំខែ មានប្រហែល ៨០% នៃករណីគ្រោះថ្នាក់ចរាចរណ៍ គឺកើតមាននៅលើផ្លូវក្រាលកៅស៊ូ និយាយរួមគឺផ្លូវរលោង។ កញ្ញាសាន សុជាតា គូសបញ្ជាក់ថា ដល់ពេលផ្លូវរលោង អ្នកធ្វើដំណើរខ្លះបើកបរយានយន្តល្បឿនជ្រុល ដោយខ្វះការអប់រំ និងខ្វះការគោរព ច្បាប់ចរាចរណ៍ផងនោះ វាក៏បង្កជាគ្រោះថ្នាក់។

បើនិយាយពីជនរងគ្រោះវិញ អ្នកដែលគ្រោះថ្នាក់ច្រើនជាងគេ គឺយុវជន មាន ១៩% ទៅ ២៣%។ កសិករមានពី ១៧% ទៅ ២៦%។ បុគ្គលិកកម្ម-ករ មានពី ១៧% ទៅ ២០%។ មេផ្ទះមានពី ៤% ទៅ ៨%។ រីឯអ្នកជំនួញមានពី ៤% ទៅ ៨% និងអ្នករត់ម៉ូតូឌុបមានពី ៤% ទៅ៦%។

សម្រាប់ពេលវេលានៃគ្រោះថ្នាក់ចរាចរណ៍វិញ គឺច្រើនកើតមាននៅចុងសប្ដាហ៍ គឺ ពីថ្ងៃសុក្រម៉ោង ៦ល្ងាច ទៅដល់ម៉ោង១២ យប់ថ្ងៃអាទិត្យ ដែលអត្រាគ្រោះថ្នាក់ មានពី ៣០% ទៅដល់ ៤០%។ បើគិតទៅតាមប្រតិទិនប្រចាំឆ្នាំ ជាទូទៅ គ្រោះថ្នាក់ចរាចរណ៍ កើនឡើងខ្ពស់បំផុត គឺក្នុងអំឡុងពេល បុណ្យទានផ្សេងៗ ដូចជា ចូលឆ្នាំចិន ចូលឆ្នាំខ្មែរ ឬក៏បុណ្យអុំទូក-ល-។ អត្រាគ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃបុណ្យ គឺកើនឡើងច្រើនជាងថ្ងៃធម្មតា យ៉ាងហោចណាស់ ក៏មួយទ្វេជាពីរដែរ។

### មូលហេតុនៃគ្រោះថ្នាក់

ក្នុងចំណោមករណីគ្រោះថ្នាក់ចរាចរណ៍ទាំងអស់ គឺជាង ៩០% បណ្ដាលមកពីកត្តាមនុស្ស មានដូចជា ការបើកបរល្បឿនពេក ការហូបគ្រឿងស្រវឹង ការមិនគោរពសិទ្ធិអាទិភាព បើកឆ្លងផ្លូវដោយពុំប្រុងប្រយ័ត្ន ការជែងវ៉ា ក្នុងស្ថានភាពគ្រោះថ្នាក់ និងការបើកបញ្ច្រាសទិសជាដើម។ ចំណែក កត្តាសល់ពីនេះ គឺបណ្ដាលមកពីផ្លូវ កត្តាអាកាសធាតុ ហើយនិងកត្តាយានយន្ត -ល-។

### តើធ្វើដូចម្ដេចដើម្បីអាចកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍?

លោកឌិន សុគន្ធ ប្រជាពលរដ្ឋមួយរូប នៅសង្កាត់បឹងកក់១ ខណ្ឌទួលគោកនៃរាជធានីភ្នំពេញ បាននិយាយថា គ្រោះថ្នាក់ចរាចរណ៍ អាចកាត់បន្ថយបាន បើសិនជាអាជ្ញាធរដាក់ផ្លាកសញ្ញាចរាចរណ៍ និងផ្លាកកំណត់ល្បឿន ឱ្យត្រឹមត្រូវ និងបានច្រើនលើដងផ្លូវ។ ប្រជាពលរដ្ឋទាំងអស់ និងគ្រប់ៗ រូបត្រូវខិតខំស្វែងយល់ និងគោរពច្បាប់ចរាចរណ៍ជាពិសេសនោះ ត្រូវតែមានការយោគយល់គ្នា ពេលបើកបរ ដែលជាសីលធម៌រស់នៅមួយដែរ។

អ្នកស្រីប្រាក់ ពិសិដ្ឋរង្សី មានប្រសាសន៍ដែរថា : “ដើម្បីកាត់បន្ថយគ្រោះថ្នាក់ គឺទី១ អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែពង្រឹងច្បាប់ចរាចរណ៍ឱ្យបានល្អប្រសើរ។ ទី២ ត្រូវអប់រំផ្សព្វផ្សាយឱ្យយល់ដឹងពីគ្រោះថ្នាក់ និងច្បាប់ ហើយទី៣ គឺប្រជាពលរដ្ឋខ្លួនឯងត្រូវយល់ដឹងអំពីសុវត្ថិភាពផ្ទាល់ខ្លួនដូចជាពេលបើកបរ មិនផឹកគ្រឿងស្រវឹងជាដើម។ អ្នកស្រី បានអំពាវនាវដល់អ្នកជិតខាង ឬសាច់ញាតិនៅពេលករណីគ្រោះថ្នាក់ កើតមានឡើង ត្រូវតែព្យាយាមបញ្ជូនជនរងគ្រោះ ទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុតឱ្យទាន់ពេលវេលា”។

ចំណែកកញ្ញាសាន សុជាតា ក៏មានគំនិតស្របនឹងអ្នកស្រីប្រាក់ ពិសិដ្ឋរង្សី គ្រាន់តែកញ្ញាធ្វើសំណូមពរបន្ថែមដល់ប្រជាពលរដ្ឋម្នាក់ៗ ពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព បើបើកបររថយន្ត និងពាក់មួកសុវត្ថិ-ភាពផងដែរ ពេលជិះម៉ូតូ។ កញ្ញារំលឹកថា ៧០% នៃគ្រោះថ្នាក់ កើតមានចំពោះមធ្យោបាយធ្វើដំណើរដោយម៉ូតូ និង ៩០% នៃជនរងគ្រោះទាំងអស់សុទ្ធតែរបួសប៉ះពាល់ក្បាល។

អត្ថបទដោយ ផាត សំភី

### ពត៌មានបន្ថែមអំពីជនរងគ្រោះបន្ទាប់ពីគ្រោះថ្នាក់

របាយការណ៍អង្គការ Handicap International ចាប់ពីខែកញ្ញា ឆ្នាំ២០០៥ ដល់ខែកុម្ភៈ ឆ្នាំ២០០៦ បានឱ្យដឹងថា ជាប្រចាំខែ មានតិចជាង ៤០%នៃជនរងគ្រោះរងរបួសធ្ងន់ដែលបានទៅមន្ទីរពេទ្យដោយរថយន្តគិលានសង្គ្រោះ។ ទំនាក់ទំនងសង្គ្រោះបន្ទាន់ (ភ្នំពេញ) : ០២៣ ៧២៤ ៨៩១។ (សៀមរាប) : ០១២ ៦៣០ ៣៩៩ / ០៦៣ ៧៦១ ១១៩។



# អភិបាលអេមីល ដេតម្យ : ជីវិតមានតម្លៃ ត្រូវតែគោរព

**ដោយមើលឃើញគ្រោះថ្នាក់ចរាចរណ៍តែងតែកើតមានច្រើនឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ជាតំណាងឱ្យព្រះសហគមន៍ លោកអភិបាលអេមីល ដេតម្យ បានមានយោបល់ដូចតទៅ :**



លោកអភិបាលអេមីល ដេតម្យ

Photo: DR

ខ្ញុំចាប់អារម្មណ៍ខ្លាំងមែនៗ ចំពោះគ្រោះថ្នាក់ចរាចរណ៍ដែលយើងឃើញមានច្រើននៅតាមដងផ្លូវ។ រៀងរាល់ថ្ងៃ ពេលយើងចេញដំណើរទៅកន្លែងផ្សេងៗ ជួនកាល យើងមានឃើញគ្រោះថ្នាក់បុកគ្នា ដែលវាបណ្ដាលឱ្យមានអ្នកស្លាប់ និងអ្នកត្រូវរបួសអ៊ីចឹងដែរ។ ប៉ុន្តែខ្ញុំមិនដឹងថា ត្រូវធ្វើយ៉ាងម៉េចដែរ ដើម្បីមិនឱ្យមានគ្រោះថ្នាក់នោះ។ ខ្ញុំជឿថា នេះអាស្រ័យលើពលរដ្ឋម្នាក់ៗ ត្រូវមានការប្រុងប្រយ័ត្នព្រោះការជិះឡាន ឬជិះម៉ូតូ ដោយគ្មានរបៀបរៀបរយនឹងធ្វើឱ្យមានកើតគ្រោះថ្នាក់ច្រើន។

នៅពេលឃើញមនុស្សស្លាប់ ខ្ញុំមានអារម្មណ៍សោកស្ដាយ។ ទោះបីខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវលើបញ្ហាចរាចរណ៍ ក៏ខ្ញុំយល់ថា យើងត្រូវរៀបចំនូវកម្មវិធីមួយ ឱ្យស្រួលជាង និងឱ្យមានរបៀបរៀបរយជាង។ ខ្ញុំចង់ឱ្យពលរដ្ឋម្នាក់ៗ ខិតខំគោរពតាមច្បាប់ឱ្យបានត្រឹមត្រូវ និងមានអធ្យាស្រ័យដល់គ្នា។

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នេះ វាគឺជាតួនាទីទាំងអស់គ្នា។ ហើយសូមកុំឱ្យយើងដាក់ទោសលើអ្នកយាមការពារវិថី ឬប៉ូលីសចរាចរណ៍។ ខ្ញុំយល់ដែរថា ម្នាក់ៗ ត្រូវតែកាន់តាមច្បាប់ចរាចរណ៍ឱ្យបានត្រឹមត្រូវ កុំគិតតែពីឈ្នះគេ កុំគិតតែពីដល់មុនគេ ដោយមិនគិតប្រយោជន៍រួម ព្រោះថា នៅលើផ្លូវ បើម្នាក់ៗ គិតចង់តែទៅដល់មុននោះ វាក៏អាចធ្វើឱ្យផ្លូវស្ទះ និងឥតមានផ្លូវសម្រាប់អ្នកណាសោះ។

ជីវិតមនុស្សយើងម្នាក់ៗ មានតម្លៃគ្រប់ៗ គ្នា គឺយើងមិនមែនមានតម្លៃ ដោយសារតែយើងមានឡានធំ ឬក៏មានម៉ូតូល្អ ជាងគេនោះទេ។ ជីវិតអ្នកដើរក៏មានតម្លៃ ដូចជាអ្នកជិះនៅក្នុងឡានដែរ។ ដោយសារជីវិតយើងម្នាក់ៗ មានតម្លៃណាស់ យើងត្រូវខិតខំគោរព តម្លៃជីវិតរបស់អ្នកដទៃដែរ។ អ៊ីចឹងបើយើងពុំបានប្រុងប្រយ័ត្ន យើងអាចគ្មានគ្រោះថ្នាក់ ប៉ុន្តែ យើងអាចបង្កើតគ្រោះថ្នាក់សម្រាប់អ្នកដទៃ។

ខ្ញុំមានសំណូមពរ សូមឱ្យម្នាក់ៗ ខំស្វែងយល់ដឹងច្បាប់ចរាចរណ៍ ឱ្យយល់ថា ផ្លូវគឺសម្រាប់ទាំងអស់គ្នា។ បើសិនជាយើងខិតខំធ្វើដំណើរដោយគោរព ច្បាប់ចរាចរណ៍ ប្រហែលស្រួលជាងនេះ។ ម្យ៉ាងវិញទៀត នៅពេលកំពុងធ្វើដំណើរ បើសិនយើងឃើញមាននូវគ្រោះថ្នាក់ យើងត្រូវខិតទៅជិតដើម្បីនឹងជួយ។ បើមានមនុស្សច្រើនសម្រាប់តែមើលនោះ វាឥតមានប្រយោជន៍ទេ។ ដូចនេះ បើគ្រោះថ្នាក់ស្រាល យើងអាចជូនគេទៅ មន្ទីរពេទ្យ ឬក៏ទៅផ្ទះ។ បើសិនធ្ងន់ធ្ងរបន្តិច យើងជួយទូរស័ព្ទ រកហៅឡានគិលានសង្គ្រោះដឹកជនរងគ្រោះទៅមន្ទីរពេទ្យ។ យើងមិនអាចធ្វើអ្វីច្រើនទេ ពីព្រោះយើងមិនមែនជាពេទ្យ។ អ្វីៗដែលយើងធ្វើជាប្រយោជន៍ដល់ជនរងគ្រោះ វាអាចជាកិច្ចការសប្បុរសធម៌មួយ។ នេះគឺជាផ្លូវតែមួយដើម្បីរស់នៅជាមួយគ្នា ដោយស្រួល ដោយគិតដល់ប្រយោជន៍អ្នកដទៃ និងប្រយោជន៍រួម។

# ព្រះសហគមន៍ នៅបន្តជួយជនក្រីក្រ

**ភូមិ-ស្រុកដែលប្រៀបបីដូចជាផ្កាស្រពោនក្រៀមស្វិតគ្មានទឹកដើម្បីបន្តជីវិតទៅមុខទៀតនោះ បានប្រែក្លាយទៅជាបុប្ផាមួយទង ដែលមានពណ៌ និងក្លិនក្រអូបសុះសាយ។ ផលវិបាកដែលប្រជាជននៅក្នុងស្រុកគូលែនបានជួបប្រទះពីមុន ឥឡូវនេះបានរលាយចេញពីខ្លួនប្រាណរបស់ពួកគេបន្តិចម្តងៗ។ ទាំងនេះក៏ដោយសារបានការជួយជ្រោមជ្រែងពីសប្បុរសជនកាតូលិកដែរ។**

## ខេត្តព្រះវិហារ

ស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា ដែលមានចម្ងាយ ២៩៤ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ដែលមានទីរួមខេត្តហៅថា: "ត្បែងមានជ័យ"។ ខេត្តព្រះវិហារយកឈ្មោះតាមប្រាសាទដែលមានឈ្មោះថា ប្រាសាទព្រះវិហារ។ ខេត្តនេះមានទំហំដី ១៣៧៨៨ គម² និងមានប្រជាជនចំនួន ១១៩២៦១នាក់ (ស្ថិតិឆ្នាំ១៩៩៨)។ ខេត្តនេះមាន ស្រុក៧ គឺស្រុកជ័យសែន឵ ឆែប ជាំក្សាន្ត គូលែន រវៀង សង្គមថ្មី និង ត្បែងមានជ័យ។ អ្នកស្រុកនៅក្នុងខេត្តព្រះវិហារមានជីវភាពក្រីក្រ ហើយក្នុងចំណោមពួកគេភាគច្រើនប្រកបការងារធ្វើស្រែ និងចំការ។

ស្ពាន ផ្លូវ ស្រះទឹក និងសាលារៀនជាច្រើន ត្រូវបានផ្តល់ជូនប្រជាជន និងសិស្សានុសិស្សឱ្យបានរៀនសូត្រ នៅក្នុងទីភូមិព្បូរជ្រូក និងភូមិគូលែនក្នុង ខេត្តព្រះវិហារ។ លោកខៀន រំ អាយុ ៤៨ឆ្នាំ ប្រធានភូមិព្បូរជ្រូក ស្រុកគូលែន បានបង្ហាញពីអារម្មណ៍រីករាយថា: "ខ្ញុំមានការសប្បាយចិត្តរកអ្វីប្រៀបផ្ទឹមពុំបាន ដែលមានសប្បុរសជនជួយសង់នូវស្ពានថ្មថ្មី ជំនួសស្ពានចាស់ ដែលបានខូចខាតអស់ហើយ"។ លោកបន្តថា នៅរដូវទឹកឡើង (ខែកញ្ញា) ស្ពានចាស់ត្រូវលិចទឹកទាំងស្រុង ដែលធ្វើឱ្យការធ្វើដំណើរមានជួបការលំបាក។

អតីតនាយកអនុវិទ្យាល័យគូលែន លោកម៉ៅ ព្រិន វ័យ ៦៥ ឆ្នាំ បានឱ្យដឹងដែរថា ស្ពាននេះផ្តល់ប្រយោជន៍ជាច្រើនព្រោះនេះជាកន្លែងមួយទាក់ទងផ្នែកសេដ្ឋកិច្ច។ ភូមិនេះអាចទាក់ទងទៅដល់ភូមិផ្សេងៗ នៅជុំវិញបាន លុះត្រាតែធ្វើការឆ្លងកាត់តាមស្ពាននេះ។ លោកបានបន្តថា នៅមុនពេលដែលពុំទាន់មានស្ពាន និងផ្លូវនេះ កូនសិស្សមានការលំបាកក្នុងការធ្វើដំណើរទៅសាលា ពីព្រោះត្រូវធ្វើការឆ្លងទឹក។

ក្នុងទឹកមុខហាក់ដូចជាអស់កម្លាំង លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្វ៊័ តំណាងគ្រប់សិទ្ធិនៃលោកអភិបាល និងបានចុះជួយប្រជាពលរដ្ឋនៅស្រុកគូលែន ខេត្តព្រះវិហារ យ៉ាងសស្រាក់សស្រាំ អស់រយៈពេលជាង ៤ឆ្នាំ មកហើយ មានប្រសាសន៍ថា: "ខ្ញុំមានគំនិតជួយដល់ប្រជាពលរដ្ឋក្រីក្រ ដោយសារតែនៅសតវត្សរ៍ទី២១ ខ្ញុំទ្រាំមើលអ្នកក្រីក្រតោកយ៉ាកពុំបាន។ ខ្ញុំជាអ្នកប្រឆាំងទៅនឹងអំពើពុករលួយ ដូច្នេះខ្ញុំធ្វើតាមពាក្យសំដីរបស់ខ្ញុំ ដែលខ្ញុំត្រូវតែជួយអ្នកជនបទ និងអ្នកក្រីក្រ"។ លោកយល់ឃើញថា អ្នកក្រីក្រជាតំណាងនៃព្រះយេស៊ូ ទោះបីជារូបលោកមិននិយាយអំពីព្រះអង្គក្តី លោកនៅតែបម្រើព្រះយេស៊ូ។ នេះជាជំនឿរបស់លោក។ លោកបូជាចារ្យ បន្តថា យើងប្រកាសដំណឹងល្អ ព្រោះព្រះបិតាស្រឡាញ់មនុស្សលោក។ បើយើងមិនស្រឡាញ់គេ តើគេធ្វើយ៉ាងណា ?។ លោកបញ្ជាក់ថា ដំណឹងល្អគឺថា "ជីវិតមានតម្លៃ"។

អ្នកស្រីឡាច ឡូត អាយុ ៥៦ឆ្នាំ ជាអ្នកជួយបណ្តុះបណ្តាលក្នុងសមាគមកោះកម្ពុជា និងជាអ្នកជួយក្នុងការធ្វើផ្លូវ ស្ពាន និងសាលារៀនជាច្រើនដល់អ្នកភូមិ និងសិស្សានុសិស្ស នៅភូមិគូលែន និងភូមិព្បូរជ្រូក និយាយថា: "ខ្ញុំចាប់ផ្តើមជួយដល់ប្រជាជនក្រីក្រនៅភូមិនេះតាំងពី ឆ្នាំ២០០២"។

គាត់បន្ថែមថា ផលដែលទទួលបានគឺជាផលប្រយោជន៍រួមពីព្រោះនៅពេលដែលមានផ្លូវ គឺយើងអាចធ្វើដំណើរបានទាំងអស់គ្នា។ ចំនុចសំខាន់នោះ គឺវាអាចឱ្យប្រជាកសិករប្រកបការងារបានងាយស្រួល និងដឹកសំភារៈបានឆាប់រហ័ស ដែលអាចធ្វើឱ្យសហគមន៍មានការរីកចម្រើន។

លោកស្រីម៉ារីក្លូដ ជាជនជាតិបារាំងដែលបានចូលរួមក្នុងការជួយប្រជាជនក្រីក្រនៅក្នុងភូមិនោះដែរ បានមានប្រសាសន៍ឱ្យដឹងថា: "នៅភ្នំពេញ ខ្ញុំស្គាល់អ្នកមានជាច្រើន ប៉ុន្តែ នៅពេលដែលមកឃើញនៅជនបទ ខ្ញុំមានការភ្ញាក់ស្មារតីយ៉ាងខ្លាំង ពីព្រោះឃើញថា ប្រជាជននៅតាមជនបទមានជីវភាពក្រីក្រមែនទែន ដែលមិននឹកស្មានដល់។ ប៉ុន្តែយើងមានការសប្បាយចិត្តដោយមើលឃើញថា ទោះបីអ្នកទាំងនោះ គ្មានមធ្យោបាយ ក៏ពួកគេមានបំណងខិតខំបម្រើខ្លួន ដើម្បីជីវិតរបស់ពួកគេអាចងើបឈរបានដូចអ្នកដទៃដែរ។

ចំណែកលោកហ្សង់ហ្សិន ណូវ៉ា ដែលជាស្វាមី បានឱ្យដឹងដែរថា តាំងពីតូចមក យើងឃើញថា ឪពុកម្តាយជួយអ្នកក្រីក្រដូច្នេះចំពោះយើង វាជារឿងធម្មតា។ យើងកើតក្នុងគ្រួសារគ្រីស្តបរិស័ទ យើងក៏ត្រូវជួយអ្នកក្រីក្រដែរ។

ក្រៅពីសមិទ្ធផលទាំងនេះ លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្វ៊័ បានផ្គត់ផ្គង់ក្មេងៗកំព្រាចំនួន ២៥០នាក់ ដោយផ្តល់ជាលុយ និងសំភារៈជាច្រើន។ កុមារីឡុំ សុភ័ក្ត្រ អាយុ ១៣ឆ្នាំ កំព្រាឪពុក និយាយថា: "ខ្ញុំស្គាល់លោកតាប៉ុងស្វ៊័ព្រោះគាត់តែងមកចែកអំណោយដល់ពួកក្មេងកំព្រា ដូចជាលុយ សាប៊ូ ស្ករ មី ស្បែកជើង និងកាតាប-ល-"។ រីឯកុមារាវ៉ាន់ ថន រៀនថ្នាក់ ទី២ និងកំព្រាឪពុកម្តាយ រស់នៅជាមួយជីដូន និយាយថា ក្នុងមួយខែៗ គេទទួលនូវប្រាក់ឧបត្ថម្ភចំនួន ១ម៉ឺនរៀល និងរបស់របរជាច្រើនទៀតពីលោកតាប៉ុងស្វ៊័។



សមាគមកាត់ដេរបង្កើតឡើងជួយដល់ស្ត្រីនៅក្នុងភូមិឱ្យមានការងារធ្វើ



សមិទ្ធផលស្ពានថ្មីត្រូវបានសាងសង់ជំនួសស្ពានចាស់ដែលខ្ទុះខ្ទោម

Photos: M. Kunthear

អ្នកនាងលាម សាឌីម អាយុ ៣៤ឆ្នាំ ជាអ្នកមើលថែទាំក្មេងកំព្រានៅតាមភូមិ បាននិយាយថា ក្នុងមួយអាទិត្យ នាងចុះសាកសួរអំពីស្ថានភាពក្មេងកំព្រាទាំងនេះ ពីរដង។ នាងបន្តថា នាងសប្បាយដែលបានធ្វើការជួយដល់ក្មេងៗ ទោះបីជានាងបានទទួលប្រាក់បៀវត្សរ៍តិចតួចក្តី ប៉ុន្តែ នាងនៅតែមានទឹកចិត្តចង់ជួយដល់ពួកគេរហូត។

មិនត្រឹមតែប៉ុណ្ណេះ លោកបូជាចារ្យប៉ុងស្វ៊័ និងអ្នកស្រីឡាច ឡូត នៅធ្វើការងារមួយទៀត គឺជួយស្ត្រីនៅតាមភូមិដោយបង្កើតសមាគមកាត់ដេរ។ សមាគមនេះបង្កើតឡើង នាឆ្នាំ ២០០៣ ដែលទល់នឹងពេលនេះ បង្រៀនបាន ៤វគ្គរួចហើយ ដោយបានជួយស្ត្រីជាច្រើនរូប។ អ្នកគ្រូហួន ប៊ុនណម អាយុ ៤២ឆ្នាំ មានប្រសាសន៍ថា សិស្សដែលមករៀននៅទីនេះមិនតម្រូវឱ្យមានអ្វីនោះទេ។ ពួកគេមករៀនដោយមិនចំណាយថវិកា ឬសំភារៈអ្វីឡើយពីព្រោះពួកគេសុទ្ធសឹងមានជីវភាពក្រីក្រលំបាក។ អ្នកគ្រូក៏បន្តថា ខោអាវដែលគេបានកាត់រួចត្រូវបានយកឱ្យជនក្រីក្រ និងក្មេងកំព្រានៅតាមភូមិ។

កញ្ញាស៊ុយ ខៀន អាយុ ២៥ឆ្នាំ អ្នកភូមិគូលែន ដែលកំពុងញាប់ដៃក្នុងការដេរខោខ្លី បានងាកមកបញ្ជាក់ដែរថា កញ្ញាមករៀនដេរខោអាវទីនេះ ទើបតែបានមួយខែទេ។ សម្រាប់ការរៀននេះ កញ្ញាគិតថា នាពេលអនាគត ការងារនេះអាចជួយដល់កញ្ញាបាន ដោយសារតែកញ្ញាពុំមានចំណេះចេះដឹងអ្វីទេ។ ចំពោះកញ្ញាសិត តម អាយុ ២៨ឆ្នាំ ក៏បានឱ្យដឹងដែរថា នាងស្រលាញ់ចូលចិត្តធ្វើការងារនេះណាស់។ នាងគិតថានេះជាមុខរបរនាងទៅថ្ងៃអនាគត។ នៅពេលរៀនចប់ នាងនឹងខិតខំសន្សំលុយដើម្បីទិញម៉ាស៊ីនមកដេរនៅផ្ទះ។

មុំ គន្ធា

## សមិទ្ធផលដែលត្រូវបានកសាង

ពីឆ្នាំ២០០៣-២០០៦ លោកបូជាចារ្យប៉ុងស្វ៊័ ជួយដល់ប្រជាជនក្នុងស្រុកគូលែនមាន: អគារសិក្សាថ្ម ៣ខ្នង សរុប ១៥បន្ទប់ ដាក់សង្ហារិមដល់អនុវិទ្យាល័យគូលែន និងសាលាបឋមសិក្សាព្បូរជ្រូក។ កសាងមត្តេយ្យ ២បន្ទប់ និងបណ្ណាល័យ ១បន្ទប់ ធ្វើបន្ទប់កុំព្យូទ័រ និងផ្ទះបាយ លើកផ្លូវថ្មីចាក់គ្រួសក្រហមប្រវែង ៨១០ម៉ែត្រ។ ជួយឧបត្ថម្ភកុមារកំព្រាក្នុងស្រុកចំនួន ២៥០នាក់។ ឧបត្ថម្ភកុមារកំព្រាជាសិស្សមកពីឆ្ងាយនូវកង់ ៣៥គ្រឿង។ ធ្វើស្ពានថ្មប្រវែង ២៥ម លើកទំនប់ប្រវែង ១១០ម ជម្រៅ ៣ម និងមានសមិទ្ធផលជាច្រើនទៀត។

# មីនជាសត្រូវដ៏ធំរបស់មនុស្សជាតិ

**បន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃជិត ៣ទសវត្សរ៍ កើតមាននៅប្រទេសកម្ពុជា បានធ្វើឱ្យប្រទេសកំសត់នេះ ជួបនឹងបញ្ហាបន្សល់ទុកជាច្រើន ដូចជាភាពក្រីក្រ ភាពខ្ទេចខ្ទាំដីស្រែចំការប្រជាពលរដ្ឋ ជីវិតមនុស្សសត្វ ពិសេសបន្សល់ទុកនូវជនពិការជាច្រើនរូប។**



រូបតូច : ទោះបីជើងពិការ ក៏កុមារីនៅតែសង្ឃឹមក្នុងជីវិត និងរូបថតថ្ងៃប្រារព្ធទិវាយល់ដឹងអំពីមីន

Photos: Fr. Kiké

នៅព្រះសហគមន៍បាត់ដំបង កាលពីថ្ងៃទី ២៣ មីនា ២០០៦ មានប្រារព្ធនូវទិវាបំផុសការយល់ដឹងអំពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដែលរៀបចំឡើងដោយមណ្ឌល អារ៉ុបពេ ដោយមានចូលរួមពីលោកអភិបាលគីកេ លោកពុកហ្គាប៊ីក ប្រធានភូមិ-ឃុំ លោកតំណាងអង្គការ CMAC បងស្រី មណ្ឌលសន្តវ៉ាំងសង់ ដឺប៉ូល បងស្រីសាលេស៊ាន គណៈកម្មការរបស់ព្រះសហគមន៍បាត់ដំបង កុមារា កុមារីនៃមណ្ឌល អារ៉ុបពេ និងបងប្អូនគ្រីស្តបរិស័ទជាច្រើនរូបទៀត។

ក្នុងឱកាសនោះ លោកវង្ស វិសាល បុគ្គលិកអង្គការ CMAC មានប្រសាសន៍ថា : "នៅប្រទេសកម្ពុជា មានបន្សល់ទុកនូវគ្រាប់មីនបន្ទាប់ពីសង្គ្រាម។ គ្រាប់មីនសម្លាប់មនុស្ស និងធ្វើឱ្យពិការយ៉ាងសាហាវបំផុត"។ លោកបន្តទៀតថា : "អំឡុងដើមឆ្នាំដល់ចុងឆ្នាំ២០០៥ CMAC បានរកឃើញ និងបោសសំអាតគ្រាប់មីនបាន ៧៣២ចំការមីន លើទំហំផ្ទៃដី ៣០០០ ហិចតា រកឃើញនូវគ្រាប់មីនប្រឆាំងមនុស្ស ៧៦៧៣គ្រាប់ ស្មើនិងមនុស្ស ៧៦៧៣នាក់ រកឃើញ និងបំផ្លាញគ្រាប់មីនប្រឆាំងរថក្រោះ ១២២៣គ្រាប់ រកឃើញនូវគ្រាប់យុទ្ធភណ្ឌពុំទាន់ផ្ទុះ ៩១២១១គ្រាប់ និងបោសសំអាតចំការមីនដើម្បីកាត់បន្ថយគ្រោះថ្នាក់តាមសហគមន៍បាន ២០០កន្លែង។

កុមារី តឹង អាយុ ១០ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ និងរស់ក្នុងមណ្ឌល អារ៉ុបពេ ពោលថា អកុសលដ៏អាក្រក់ បានកើតមានឡើងចំពោះរូបនាងនៅឆ្នាំ២០០៥ គឺពេលនាងទៅចាក់អន្ទ្រងជាមួយម្តាយ និងបងស្រី ហើយបានជាន់មីន។ "ជើងឆ្វេងក្រោមជង្គង់ខ្ញុំត្រូវដាច់។ "ខ្ញុំសន្លប់មិនដឹងខ្លួន រីឯម្តាយខ្ញុំរបួសដៃឆ្វេងយ៉ាងធ្ងន់" កុមារី តឹង និយាយដោយទឹកមុខស្រពោន។ នាងបន្តថា ហេតុការណ៍នេះធ្វើឱ្យ នាងភ័យតក់ស្លុតបំផុត និងចងចាំមិនភ្លេចថា មីនបានសម្លាប់បងស្រីនាង ២នាក់ ធ្វើឱ្យម្តាយរបួស រីឯនាងត្រូវពិការអស់មួយជីវិត។

### ស្វែងយល់ពីមីន

គិតមកដល់ឆ្នាំ២០០៥ មាន ១៥៤ប្រទេស ដែលបានចុះហត្ថលេខាសន្ធិសញ្ញាលុបបំបាត់មីន ក្នុងនោះ ១៤៧ប្រទេស ជាភាគីរដ្ឋសមាជិកសន្ធិសញ្ញា។ ប្រទេសផលិតគ្រាប់មីនមានចំនួន ១៣ គឺមាន ភូមា ចិន គុយបា ឥណ្ឌា អ៊ីរ៉ង់ កូរ៉េខាងជើង កូរ៉េខាងត្បូង នេប៉ាល់ ប៉ាគីស្ថាន រុស្ស៊ី សិង្ហបុរី អាម៉េរិក និងវៀតណាម។ នៅក្នុងឆ្នាំ ២០០៤ ផ្ទៃដីដែលបានដោះមីនចេញមាន ១៣៥ គម$^{2}$ និង១៧០គម$^{2}$ ជាតំបន់ប្រទាញប្រទង់គ្នា។

កុមារា ណេង អាយុ ១៥ឆ្នាំ ពិការនូវជើងទាំង២ និងដៃឆ្វេងម្ខាង និយាយថា គេសោកស្តាយជាខ្លាំង ដែលធ្លាក់ខ្លួនពិការដោយសារគ្រាប់មីន ធ្វើឱ្យក្តីសង្ឃឹមតាំងពីតូចរបស់គេ ត្រូវបានរលាយ។ កុមារដ៏កំសត់នេះ បន្តថា ខ្ញុំមិនចង់ជួបមនុស្សផ្សេងៗ ទៅសាលារៀន ឬលេងជាមួយមិត្តភក្តិរបស់ខ្ញុំពីមុនទៀតឡើយ។ ប៉ុន្តែពេលនេះ កុមារា ណេង បានទៅរៀនដូចកុមារដទៃទៀតដោយសារមណ្ឌល អារ៉ុបពេ ជួយ។ កុមារា ណេង ផ្តែផ្តាំថា : "កុំភ្លេចថា មីនគឺជាឃាតកលាក់ខ្លួន"។

នៅក្នុងឱកាសនោះ លោកអភិបាលគីកេមានប្រសាសន៍ថា : "ខ្ញុំមានអំណរសប្បាយ ដែលយើងបានរួមជាមួយគ្នា នៅថ្ងៃនេះក្នុងបរិវេណព្រះវិហារ ដើម្បីចាប់អារម្មណ៍រិះគិតពីបញ្ហាមីន"។ លោកបន្តថា តាមរយៈអង្គការ CMAC និងអង្គការផ្សេងៗគាំទ្រជនពិការបង្ហាញថា គ្រោះថ្នាក់ដោយសារគ្រាប់មីនកើនឡើងជារឿយៗ ដែលភាគច្រើន នៅខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ និងក្រុងប៉ៃលិន។ នេះជាបញ្ហាធំ ដែលប្រទេសជាតិទទួលឥទ្ធិពលពីសង្គ្រាម។ លោកអភិបាល ក៏ផ្តែផ្តាំថា ដើម្បីស្វែងរកភូមិមួយ ប្រទេសមួយ ដែលមានសន្តិភាព និងអនាគតល្អ យើងត្រូវតែចូលរួមដូចថ្ងៃនេះ ដើម្បីសហការគ្នា រិះគិតរួមគ្នាអំពីបញ្ហាគ្រាប់មីន និងស្វែងរកសន្តិភាពជូនជាតិមាតុភូមិ ដូចជារចាំព្រាបស សន្តិភាព។

សុជាតិ





# ផ្តាសាយបក្សី

**សុខភាពគឺជាបញ្ហាសំខាន់សម្រាប់មនុស្សគ្រប់រូប ដែលត្រូវមានការយល់ដឹង និងយកចិត្តទុកដាក់។ តើអ្នកធ្លាប់ឮពីជំងឺគ្រុនផ្តាសាយបក្សីទេ ? តើអ្នកត្រូវការពារខ្លួនយ៉ាងណាដើម្បីកុំឱ្យឆ្លងជំងឺនេះ ?**

### អ្វីជាជំងឺគ្រុនផ្តាសាយបក្សី ?

គ្រុនផ្តាសាយបក្សីជាជំងឺឆ្លងរបស់សត្វបណ្តាលមកពីមេរោគ ដែលជាធម្មតា ឆ្លងរាលដាល តែក្នុងចំណោមពពួកសត្វបក្សីគ្រប់ប្រភេទ ហើយវាកម្រនឹងឆ្លងពីសត្វមកមនុស្សណាស់។ ជំងឺនេះបង្កឡើងដោយវីរុស ឈ្មោះថា អាំងប្លូអង់ស្សា គឺជាឈ្មោះរបស់វីរុសមួយប្រភេទ ដែលរយៈពេលធ្វើឱ្យអ្នកជំងឺស្លាប់ជាមធ្យម គឺពី៨ ទៅ១០ថ្ងៃតែប៉ុណ្ណោះ។

លោកលី សូវ៉ាន់ អនុប្រធាន នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល មានប្រសាសន៍ឱ្យដឹងថា ជំងឺនេះមានអាការៈស្រដៀងនឹងជំងឺផ្តាសាយ ប៉ុន្តែចម្លែក គឺអ្នកជំងឺមានគ្រុនក្តៅខ្លាំង ក្អក ពិបាកដកដង្ហើមដូចជាថប់ៗ រោយឆ្អឹងខ្នង ឈឺសាច់ដុំ និងឈឺក្បាលជាដើម។ លោកក៏បន្តថា នៅកម្ពុជា មានមនុស្សស្លាប់ដោយជំងឺនេះ ៦នាក់ហើយ ដែលកើតមានលើកូនក្មេង និងមនុស្សវ័យជំទង់ពី២០ ឬ៣០ឆ្នាំ។ មេរោគជំងឺនេះ នឹងងាប់នៅសីតុណ្ហភាព ១០០អង្សា ដែលសីតុណ្ហភាព ៦០អង្សា វារស់បាន កន្លះម៉ោង ៥៥អង្សា អាចរស់បាន ៣ម៉ោង និង០អង្សា រស់បានមួយខែ។ មេរោគនេះរស់នៅក្នុងលាមកសត្វ ទឹករំអិលរបស់សត្វ-មនុស្ស និងក្នុងទឹកបានរយៈពេលបីថ្ងៃ។ លោកសូវ៉ាន់ ប្រាប់ថា អ្នកដែលប្រឈមខ្ពស់នឹងជំងឺនេះ គឺម្ចាស់កសិដ្ឋានចិញ្ចឹមមាន់ទា អ្នកដឹកលក់មាន់ទា និងអ្នកសម្លាប់អាជីប។ ដើម្បីការពារកុំឱ្យឆ្លងជំងឺ អ្នកដែលប្រឈមមុខទាំងនោះត្រូវពាក់ម៉ាស់ ស្រោមដៃ និងស្បែកជើងកវែង។ ចំពោះប្រជាកសិករ ឬមនុស្សទូទៅ សូមកុំហូបមាន់ទាឈឺ ឬងាប់ឱ្យសោះ គឺត្រូវយកមាន់ទាឈឺ ឬងាប់ទៅកប់ឱ្យជ្រៅ រួចលាងដៃនឹងសាប៊ូ។ ប៉ុន្តែពួកគេអាចហូបបាន លុះត្រាតែវាត្រូវបានចម្អិនឆ្អិនល្អ។ ថ្នាំសម្រាប់ព្យាបាលជំងឺ គឺតាមីផ្លូ Tamiflu ប៉ុន្តែមិនអាចប្រើផ្តេសផ្តាសបានទេ។ បើសិនសង្ស័យថាមានជំងឺនេះ សូមទូរស័ព្ទមកលេខ : ០១២ ៥៥ ៥០ ០២ ៧០ ៨៥

មុំ គន្ធា




ផ្ទាំងប៉ាណូអប់រំដល់ប្រជាពលរដ្ឋអំពីគ្រោះថ្នាក់នៃជំងឺគ្រុនផ្តាសាយបក្សី

Photo: Ministry of Health

### យុទ្ធសាស្ត្រទាំង ៥ របស់ក្រសួងសុខាភិបាល

ពង្រឹងការផ្សព្វផ្សាយ អប់រំដល់ប្រជាជន និងគ្រូពេទ្យ។ ពង្រឹងប្រព័ន្ធតាមដានអង្កេតស្រាវជ្រាវ។ ពង្រឹងការងារពិនិត្យព្យាបាល ដល់មន្ត្រីជំនាញ។ ពង្រឹងការគាំទ្រឱសថ សំភារៈបរិក្ខារ។ ពង្រឹងគុណភាពមន្ទីរពិសោធន៍ និងត្រៀមផែនការការពារឆ្លងពីមនុស្សមកមនុស្ស។

## អន្តរជាតិ

# លោកអភិបាលជៀត្រូវបានដោះលែង

**លោកអភិបាលនៃប្រទេសចិនភាគខាងជើងត្រូវបានដោះលែងកាលពីថ្ងៃទី១៩ មេសាកន្លងទៅនេះ បន្ទាប់ពីជាប់ឃុំឃាំងរយៈពេល៥ខែ តែនៅមានការឃ្លាំមើលពីមន្ត្រីរដ្ឋាភិបាល។**

លោកអភិបាល ហ្សូលីយូស ជៀ ហ្ស៊ីហ្គូ Julius Jia Zhigou នៃទីក្រុងហ្សេងឌីង Zhengding ជាអ្នកដែលមិនចូលរួមជាមួយរដ្ឋាភិបាល ត្រូវបានត្រឡប់ទៅកាន់ព្រះវិហារ ក្នុងភូមិវូគី Wuqui ខេត្តហេប៊ី Hebei វិញហើយ។ ប៉ុន្តែ លោកមានសេរីភាពតិចតួច នៅក្នុងបរិវេណព្រះវិហារ ជាកន្លែង ដែលលោកប្រារព្ធពិធីអភិបូជា និងជួបប្រជុំគ្រីស្តបរិស័ទរាល់ព្រឹក ពីព្រោះមានមន្ត្រីរដ្ឋាភិបាលធ្វើការតាមដានលោក នៅពេលដែលលោកចេញសួរសុខទុក្ខគ្រួសារគ្រីស្តបរិស័ទ។ គ្រីស្តបរិស័ទម្នាក់ ដែលបានជួបលោកអភិបាលនៅខាងក្រៅព្រះវិហារនិយាយថា មន្ត្រីរដ្ឋាភិបាលឃ្លាំមើលពួកយើង ដូចនេះ លោកអភិបាលពុំបានប្រាប់យើងពី មូលហេតុដែលគាត់ត្រូវឃុំឃាំង ឬមានអ្វីកើតឡើងខណៈដែលគាត់ជាប់ឃុំទេ។ លោកបូជាចារ្យខ្លះនៃភូមិភាគហ្សេងឌីង បញ្ជាក់ថា លោកអភិបាលជៀត្រូវឃុំឃាំងពីព្រោះលោកមិនទទួលយក "ឯករាជ្យភាព ក្នុងការគ្រប់គ្រងព្រះសហគមន៍ខ្លួនឯង" និង "ការតែងតាំងអភិបាលដោយខ្លួនឯង"។

UCANews

## ក្មេងប្រុសកំពុងដេញតាមសត្វដែលបានឆក់យកសាច់ក្រករបស់គេ។ ដោយគូសភ្ជាប់ពីចំនុច១ ដល់៣៤ ប្រិយមិត្តនឹងដឹងថា សត្វអ្វីដែលជាចោរលួចចំណី។





# អ្នកកាសែត

**មនុស្សរស់នៅត្រូវការដឹងអំពីព័ត៌មាននៅជុំវិញខ្លួន។ ព័ត៌មានជិតៗ គេអាចដឹងបានដោយខ្លួនឯង តែព័ត៌មានដែលកើតនៅកន្លែងឆ្ងាយៗ គឺជាតួនាទីអ្នកកាសែត ដែលនាំព័ត៌មាននោះឱ្យគេបានដឹង។**

Photo: H. Soktheary



អ្នកកាសែតត្រូវតែទៅសម្ភាសន៍សិន ទើបអាចសរសេរជាអត្ថបទ

បើតាមប្រសាសន៍របស់លោកជា ប៊ុនធឿន ដែលជាអ្នកយកព័ត៌មានប្រចាំកាសែត សំណេរថ្មី ជាកាសែតតំបន់ បានប្រាប់ឱ្យដឹងថា អ្នកកាសែត គឺជាអ្នកពាំនាំព័ត៌មានប្រាប់ឱ្យមហាជនបានដឹង ហើយព័ត៌មាននោះ ត្រូវតែពិតប្រាកដ សំខាន់ទាន់ហេតុការណ៍ និងដែលអ្នកដទៃចង់ដឹង។

មុននឹងចេញទៅយកព័ត៌មាន អ្នកកាសែត គិតជាមុនថា តើត្រូវសរសេរព័ត៌មានអំពីប្រធានបទអ្វី ? និងត្រូវការទៅជួបនរណា ?។ រួចហើយគេប្រើសំនួរ អ្វី? នរណា? ពេលណា? កន្លែងណា? និងហេតុអ្វី? ដើម្បីសួរអ្នកផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងប្រធានបទ។ ចុងក្រោយ គេក៏ត្រូវសរសេរយ៉ាងណាឱ្យព័ត៌មាន បានគ្រប់ជ្រុងជ្រោយ និងទាក់ទាញចំណាប់អារម្មណ៍អ្នកអានទៀតផង។

លោកជា ប៊ុនធឿន សង្កត់ធ្ងន់ថា អ្នកកាសែតត្រូវព្យាយាមទាក់ទងជាមួយមនុស្សឱ្យបានច្រើនបំផុត គ្រប់ទីកន្លែង និងគ្រប់ស្ថាប័ន។ យើងត្រូវប្រាប់អ្នកទាំងនោះថា បើមានព័ត៌មានអ្វី សូមរាយការណ៍ប្រាប់យើង។ យើងគឺជាអ្នកកាសែតត្រូវតែដឹងព័ត៌មានឱ្យបានមុនគេ។ ហើយបើចង់ដឹងថា ព័ត៌មាននោះ អ្នកអានចាប់អារម្មណ៍ដែរឬទេ? យើងត្រូវដើរតួយើងជាអ្នកអានមុនសិន។ បើសិនយើងចាប់អារម្មណ៍ អ្នកផ្សេងៗ ប្រហែលជាចាប់អារម្មណ៍ដែរហើយ។ លោកបន្តថា អ្នកកាសែតមួយរូបដ៏ល្អ គឺជាមនុស្សដែលគោរពវិជ្ជាជីវៈខ្លួន ដោយសរសេរព័ត៌មានជាអ្នកកណ្តាល អ្នកអព្យាក្រិត និងក៏មិនប្រកាន់បក្សខាងណាៗ ឡើយ។

អ្នកកាសែតដែលធ្វើការក្នុងស្ថាប័នណាមួយជាក់លាក់ ប្រាក់ខែរបស់គេតិច ឬច្រើន គឺវាអាស្រ័យលើការសរសេរបានល្អ បទពិសោធន៍ល្អ និងលើការចរចារវាងបុគ្គលិក និងប្រធាន។ នៅមានអ្នកកាសែតសេរីដែលសរសេរអត្ថបទសម្រាប់លក់ គេគិតមួយអត្ថបទគឺទំហំ មួយទំព័រកន្លះ A4។ ចំណែកតម្លៃវិញនោះ ក៏វាអាស្រ័យលើការព្រមព្រៀងគ្នាដែរ។

លោកជា ប៊ុនធឿន អះអាងទៀតថា ដើម្បីរៀនកាសែត ឱ្យបានល្អ យើងត្រូវមានការខិតខំព្យាយាម ដោយខ្លួនឯង គួបផ្សំនិង សាលាដែលមានសម្ភារៈឧបទេសគ្រប់គ្រាន់ គ្រូដែលមានបទពិសោធន៍ និងការអនុវត្តជាក់ស្តែងលើការងារ។

ផាត សំភី

### ព័ត៌មានសិក្សា

ការរៀនជំនាញកាសែតមាននៅសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សិក្សារយៈពេល ៤ឆ្នាំ ដោយបង់ថ្លៃសិក្សា ១ត្រីមាស ចំនួន១៦០$។ ទូរស័ព្ទ: ០២៣ ៩៩០ ១៥៣។ សកលវិទ្យាល័យភូមិន្ទភ្នំពេញ សិក្សារយៈពេល ៤ឆ្នាំ ឥតបង់ប្រាក់ តែត្រូវធ្វើការប្រលងចូលលើមុខវិជ្ជាពីរ គឺចំណេះដឹងទូទៅ និងភាសាអង់គ្លេសដែលក្នុងនោះក៏មានការធ្វើសម្ភាសន៍ផ្ទាល់មាត់ដែរ។



# ជំងឺដំបៅអំបែកបង្កគ្រោះថ្នាក់

**មិនថាមនុស្ស ឬសត្វនៅលើលោកនេះអាចស្តាប់ឮ ឬយល់អំពីបញ្ហាអ្វីមួយបានដោយសារតែត្រចៀក តែបើវាមានបញ្ហា តើយើងត្រូវធ្វើការព្យាបាល ឬការពារដូចម្តេចខ្លះ?**

ដំបៅត្រចៀក ឬដំបៅអំបែក គឺជាជំងឺតែងកើត តាមធម្មតាក្នុងវ័យកុមារភាព ហើយបើគ្មានការព្យាបាលដំបៅត្រចៀកឱ្យជាសះស្បើយ វាអាចបណ្តាលឱ្យបាត់បង់ការស្តាប់ឮ បានទាំងស្រុង។ អ្នកនាងគិត សរផានី អ្នកទទួលបន្ទុកខាងផ្នែកព្យាបាលត្រចៀកនៃអង្គការជេអេស មានប្រសាសន៍ថា ជំងឺដំបៅអំបែកនេះច្រើនកើតចំពោះមនុស្សគ្រប់វ័យ ជាពិសេសកុមារចាស់ខែ ឬអាយុ ពី២ ឬ៣ខែ ឬទារកទើបកើត ដែលងាយកើតជំងឺនេះ ពីព្រោះប្រវែងបំពង់ ដែលភ្ជាប់ពីបំពង់កទៅត្រចៀកខ្លីជាងមនុស្សពេញវ័យ។ ក្មេងដែលកើតជំងឺនេះបញ្ចេញអាការៈ ដូចជា យំ គ្រុនសរអង្កែល ចំហៀងក្បាល ឬទាញស្លឹកត្រចៀកខ្លួនឯង។ កំដៅខ្លួនមាន រវាង៣៧.៧ និង៤០អង្សាសេ ហៀរសំបោរ ឈឺបំពង់ក និងក្អក។ល។

មនុស្សភាគច្រើនតែងគិតថា នេះជាជំងឺមួយធម្មតា ប៉ុន្តែវាអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត ប្រសិនជាយើងមិនព្យាបាលបានទាន់ពេល ដោយវាអាចប៉ះពាល់ ដល់ខួរក្បាល រលាកខួរក្បាល ធ្វើឱ្យឈឺក្បាលរហូតដល់ស្លាប់ ពីព្រោះ ជួនកាល វាមិនហៀរទឹក (ជាតិខ្ទុះ) ចេញមកខាងក្រៅទេ គឺថាមេរោគស៊ីឡើងទៅខួរក្បាលតែម្តង។

ដើម្បីការពារជំងឺនេះ គឺដាច់ខាត កុំឱ្យទឹកចូលត្រចៀក ជូតត្រចៀកឱ្យស្ងួតក្រោយងូតទឹក។ បើផ្តាសាយត្រូវព្យាយាមលេបថ្នាំ។ ចូរបំបៅទឹកដោះទារក ឱ្យបាន ២ឆ្នាំ ព្រោះវាជួយទារកប្រឆាំងនឹងជំងឺនេះ ជួយពង្រឹងសាច់ដុំ ដែលរក្សាបំពង់ភ្ជាប់រវាងបំពង់ក និងរក្សាត្រចៀកផ្នែកកណ្តាលបើកចំហ។ ត្រូវឱ្យកុមារចេះជូតសំបោរ ជាជាងញើសសំបោរ បើញើសសំបោរ គួរញើសថ្នមៗ។ ឱ្យកុមារនៅឆ្ងាយពីផ្សែង និងនៅពេលសង្ស័យថា មានជំងឺនេះត្រូវទៅជួបអ្នកឯកទេសផ្នែកត្រចៀក ដោយធ្វើការលាងសំអាត ឬលេបថ្នាំ។

មុំ គន្ធា

Photo: M. Kunthear



គិត សរផានី ទទួលបន្ទុកជំងឺត្រចៀកនៃអង្គការជេអេស

### ពំនុះត្រចៀក :

ចែកជា៣ផ្នែកសំខាន់ៗ គឺខាងក្រៅ កណ្តាល និងខាងក្នុង។ ត្រចៀកខាងក្រៅជាផ្នែកអាចមើលឃើញ។ ឯផ្នែកកណ្តាល និងខាងក្នុង គឺស្ថិតនៅក្នុងខួរក្បាល និងមិនអាចមើលឃើញ។



សូមថ្វាយសព្ទសាធុការពរចំពោះព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គមានព្រះជន្មាយុយឺនយូរប្រកបដោយវិបុលភាពគ្រប់ប្រការ នៅក្នុងរាជពិធីបុណ្យចំរើនព្រះជន្មាយុព្រះអង្គ ក្រាបបង្គំទូលថ្វាយពីថ្នាក់ដឹកនាំ និងបុគ្គលិកនៃការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

## ព្រឹត្តិការណ៍សំខាន់ៗ

- ថ្ងៃ០១ ឧសភា : ការសំណាក់ធម៌ក្រុមវ៉ាំងសង់ ដឺប៉ូល ដែលធ្វើឡើងនៅព្រះសហគមន៍កំពង់ចាមក្រុង។
- ថ្ងៃ០៦ ឧសភា : ការអធិដ្ឋានតេហ្សេ ដែលដឹកនាំដោយបងប្រុសគីលេមកពីប្រទេសបារាំង វេលាម៉ោង ៦:៣០នាទីរសៀលនៅផ្សារតូច ភ្នំពេញ។
- ថ្ងៃ០៧ ឧសភា : សំណាក់ធម៌យុវជនទាំង៣ភូមិភាគ ៥០នាក់ នៅជុំនបូស្គូទឹកថ្លា រាជធានីភ្នំពេញ។
- ថ្ងៃ១០ ឧសភា : ប្រជុំក្រុមប្រឹក្សាណែនាំព្រះសហគមន៍ភូមិភាគភ្នំពេញអំពីកម្មវិធីបុណ្យ និងបញ្ហានានានៅផ្សារតូច។
- ថ្ងៃ១៤ ឧសភា : ពិធីជ្រមុជទឹកក្មេងៗ ៣៤នាក់ ដែលឪពុកម្តាយជាគ្រីស្តបរិស័ទនៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃ១៤ ឧសភា : ព្រះសហគមន៍កំពង់ចាម រៀបចំការប្រជុំកម្មការីនីកាត់ដេរ ដែលធ្វើការនៅភ្នំពេញ។
- ថ្ងៃ១៥ ឧសភា : ព្រះសហគមន៍កំពង់-ចាម ធ្វើពិធីសំណាក់ធម៌អ្នករៀនអប់រំជំនឿ២០នាក់ ត្រៀមចូលព្រះសហគមន៍។
- ថ្ងៃ១៦ ឧសភា : សំណាក់ធម៌យុវជនក្នុងមណ្ឌលនៅកំពង់ចាមលើប្រធានបទជីវិតជាគ្រីស្តបរិស័ទ។
- ថ្ងៃ២៤ ឧសភា : ប្រជុំបងស្រី និងបូជាចារ្យភូមិភាគកំពង់ចាមប្រចាំខែ។
- ថ្ងៃ២៥ ឧសភា : ពិធីត្រាស់ហៅចូលព្រះសហគមន៍កាតូលិកធ្វើនៅកំពង់ចាម។
- ថ្ងៃ០៤ មិថុនា : បុណ្យព្រះវិញ្ញាណយាងមក និងពិធីបុណ្យលាបថ្វាសដែលធ្វើនៅព្រះសហគមន៍ផ្សារតូច ភ្នំពេញ។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ ហ៊ែរណាន់ ពីនីយ៉ា